# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៥ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយសារការជួញដូរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥.០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ លេខ ១៣២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ ដើម្បីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ១៣ សរណន ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការពង្រឹង និងពង្រីកចលនាការងារប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយសារការជួញដូរ ដែលបានចុះហត្ថលេខានាថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥
- ពិនិត្យសំណូមពរការងារចាំបាច់សម្រាប់កិច្ចសហប្រតិបត្តិការដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយសារការជួញដូរ នៃប្រទេសទាំងពីរ

## ស ម្រេ ច

**ប្រការ ១ ..**

បង្កើតក្រុមការងារអន្តរក្រសួង "ដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ" សរសេរកាត់ថា **ក.ក.វ.ល.ជ.** ។

**ប្រការ ២ ..**

**ក.ក.វ.ល.ជ** មានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ១ រូប | ប្រធាន |
| ២- តំណាង ក្រសួងមហាផ្ទៃ | ១ រូប | អនុប្រធាន |
| ៣- អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ១ រូប | អនុប្រធាន |
| ៤- អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | អនុប្រធាន |
| ៥- តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១ រូប | សមាជិក |
| ៦- តំណាង ក្រសួងទេសចរណ៍ | ១ រូប | សមាជិក |
| ៧- តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| ៨- តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | សមាជិក |
| ៩- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| ១០- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |

| | | |
|---|---|---|
| ១១- តំណាង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ១ រូប | សមាជិក |
| ១២- តំណាង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ១ រូប | សមាជិក |
| ១៣- តំណាង គងរាជអាវុធហត្ថលើផ្ទៃប្រទេស | ១ រូប | សមាជិក |
| ១៤- តំណាង ក្រសួងកិច្ចការនារី | ១ រូប | លេខាធិការអចិន្ត្រៃយ៍ |

**ប្រការ ៣ .-**

គ.គ.វ.ល.ជ. មានភារកិច្ចដូចតទៅ ÷

- រៀបចំផែនការសកម្មភាពជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀង ឆ្នាំ ២០០៦- ២០០៧ និងបណ្តា ២ ឆ្នាំ បន្តបន្ទាប់ទៀត
- រៀបចំផែនការសកម្មភាពរួមដើម្បីអនុវត្តកិច្ចព្រមព្រៀង ដោយសហការជាមួយក្រុមការងារវៀតណាមសម្រាប់ ឆ្នាំ ២០០៦-២០០៧ និងបណ្តា ២ ឆ្នាំបន្តបន្ទាប់ទៀត
- ផ្តួចផ្តើមគំនិតក្នុងការរៀបចំយុទ្ធសាស្ត្រគោលការណ៍ បទប្បញ្ញត្តិចាំបាច់នានាដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ
- លើកឡើងនូវអនុសាសន៍ សំដៅឱ្យមានការរីកចម្រើនតទៅទៀត នូវកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមក រវាងប្រទេសទាំងពីរ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង និងធ្វើរបាយការណ៍ជូនគណៈកម្មការរួមនៃកិច្ចសហប្រតិប្រត្តិការទ្វេភាគីកម្ពុជា និងវៀតណាម ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន
- ពិនិត្យឡើងវិញ និងវាយតម្លៃនូវការអនុវត្តកិច្ចព្រមព្រៀងនេះរៀងរាល់ ២ឆ្នាំម្តង ដើម្បីដកបទពិសោធន៍ សម្រាប់ឆ្នាំបន្តទៀត និងរាយការណ៍ជូនរាជរដ្ឋាភិបាល
- ជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា
- លើកគម្រោងស្នើថវិកាជាតិ និងជំនួយពីអង្គការអន្តរជាតិនានា ដើម្បីបម្រើសកម្មភាពរបស់ក្រុមការងារនេះ
- ដោះស្រាយការខ្វែងមតិគ្នាលើការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ តាមរយៈការចរចា។ ក្នុងករណីមិនអាចព្រមព្រៀងគ្នាតាមរយៈការចរចាទេនោះ ការខ្វែងមតិទាំងនេះត្រូវរាយការណ៍ជូនរដ្ឋាភិបាល នៃភាគីទាំងពីរដើម្បីដោះស្រាយ
- បង្កើត និងដឹកនាំប្រតិបត្តិការនៃក្រុមការងារដូចមានចែងក្នុងប្រការ ១២ នៃកិច្ចព្រមព្រៀង

**ប្រការ ៤ .-**

សមាជិក គ.គ.វ.ល.ជ. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំបាន។ ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ។

**ប្រការ ៥.-**

គ.ក.វ.ល.ជ. មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅនាយកដ្ឋានការពារផ្លូវច្បាប់ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ។

**ប្រការ ៦.-**

ក្រុមការងារ គ.ក.វ.ល.ជ. ក្នុងករណីចាំបាច់អាចស្នើបង្កើតក្រុមការងារសម្របសម្រួលថ្នាក់ខេត្ត ក្រុង ដែលមានសមាសភាពពីតំណាងអាជ្ញាធរដែនដីដែលពាក់ព័ន្ធ ដើម្បីបង្ក្រាបការជួញដូរមនុស្ស និងផ្តល់កិច្ចការពារដល់ជនរងគ្រោះ និងប្រធំដំណើរការធ្វើមាតុភូមិនិវត្តន៍ស្ត្រី និងកុមារ ដែលត្រូវគេជួញដូរឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម ។ ក្រុមការងារថ្នាក់ខេត្ត ក្រុងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ខេត្ត ក្រុង ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបណ្តាសមាសភាពដែលមានចែងក្នុងប្រការ ២ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

អគ្គលេខាធិការរាជរដ្ឋាភិបាល

រាជកិច្ច

ឯកសារ-កាលប្បវត្តិ